# 소망의 여인들

## Prayer Calander

**2024년 11월**

**ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់**




**ការអធិស្ឋានសម្រាប់ស្ត្រីនៅអាហ្វ្រិកខាងលិច 1**

ប្រទេស Côte d'Ivoire ជាប្រទេសមួយក្នុងចំនោមប្រទេសចំនួន 23 នៅអាហ្វ្រិកខាងលិច និងកណ្តាល ដែលមានស្ថិរភាពចាប់តាំងពីការងើបឡើងវិញពីសង្គ្រាមស៊ីវិលរបស់ខ្លួនក្នុងឆ្នាំ 2011។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តំបន់ទាំងនេះបានជួបប្រទះនឹងវិបត្តិដ៏ស្មុគស្មាញ និងអូសបន្លាយជាច្រើនដូចជា៖ អំពើហិង្សាដ៏ឃោរឃៅ អស្ថិរភាពនៃនយោបាយ បម្រែបម្រួលអាកាសធាតុ អភិបាលកិច្ចមានការចុះខ្សោយ ភាពក្រីក្របានកើតឡើងក្នុងសង្គមដែលបែកបាក់ និងសហគមន៍ដែលផ្លាស់ទីលំនៅ។ ជារៀងរាល់ឆ្នាំ ក្រុមស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេសកូតឌីវ័រ បានផលិតកម្មវិធីប្រចាំសប្តាហ៍ ដែលចាក់ផ្សាយតាមវិទ្យុក្នុងស្រុក ហើយចែកចាយតាមបណ្តាយFacebook និងការស្តាប់តាមក្រុម។ សូមអធិស្ឋានសម្រាប់ព័ន្ធកិច្ចនៅ Côte d'Ivoire ក្នុងការដែលពួកគេបាននាំព្រះនាមព្រះយេស៊ូវទៅដល់ស្ត្រីដែលកំពុងស្ថិតនៅក្នុងភាពចលាចលមួយនេះ។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 한국어 기도카드를 받으실 수 있습니다.

1. ព្រះអម្ចាស់អើយ សូមអោយព្រះវិញ្ញាណរបស់ទ្រង់បានពង្រឹងទំនាក់ទំនងរវាងអង្គការនានា ដែលកំពុងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដើម្បីអោយពួកគេអាចមានឥទ្ធិពលកាន់តែខ្លាំងឡើង។ (ភីលីព ២:២)

2. ព្រះអង្គអើយ សូមប្រទានកម្លាំងដល់ស្ត្រីនៅប្រទេសបេនីន ដែលត្រូវបានបៀតបៀនដោយសារសេចក្តីជំនឿរបស់ពួកគេ ហើយត្រូវបានប្តី និងក្រុមគ្រួសារពួកគេបោះបង់ចោល។ សូមឱ្យពួកគេនៅជាប់ជាមួយទ្រង់យ៉ាងខ្ជាប់ខ្ជួន។ (១ពេត្រុស ៣:១៤)

3. បិតាអើយ សូមអោយស្វាមីនៅសាធារណរដ្ឋអាហ្វ្រិកភាគកណ្តាល ដែលបានបោះបង់ចោលប្រពន្ធដែលមានផ្ទៃពោះ បានត្រឡប់ទៅមើលថែ និងដឹកនាំគ្រួសារពួកគេដោយក្តីស្រឡាញ់វិញ។ (អេភេសូរ ៥:២៥)

4. ព្រះអង្គអើយ សូមអោយស្ត្រីនៅលីវនៅប្រទេសកូតឌីវ័រទទួលបានជំនាញ និងស្វែងរកការងារដែលមានស្ថេរភាពដែលផ្តល់ប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់តម្រូវការគ្រួសាររបស់ពួកគេ។ (ទំនុកតម្កើង ៩០:១៧)

5. ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញាដល់មេដឹកនាំនៃប្រទេសហ្គាបុង ដើម្បីឱ្យពួកគេអាចគ្រប់គ្រងទ្រព្យសម្បត្តិធម្មជាតិរបស់ប្រទេសបានត្រឹមត្រូវ និងទ្រទ្រង់ធនធានរបស់ពួកគេផងដែរ។ (សុភាសិត ២:៦)

6. ឱ ព្រះវរបិតាអើយ សូមលើកតម្កើងពួកអ្នកជឿនៅប្រទេសលីបេរីយ៉ា ដែលពួកគេនឹងមានការលើកទឹកចិត្តដល់ស្ត្រីមេម៉ាយខាងឯព្រលឹងវិញ្ញាណ សូមនាំពួកគេទៅរកការព្យាបាលផ្លូវចិត្ត និងជួយពួកគេឱ្យទទួលបានឯករាជ្យភាពខាងសេដ្ឋកិច្ចផងដែរ។ (ទំនុកតម្កើង ៦៨:៥)

7. ព្រះអម្ចាស់អើយ សូមបំផុសគំនិតគ្រីស្ទបរិស័ទដែលកំពុងស្វែងដៃគូជីវិតនៅប្រទេសម៉ាលី សូមអោយពួកគេបានរង់ចាំបុរស និងស្ត្រីដែលគោរពកោតខ្លាចព្រះ។ សូមឱ្យអាពាហ៍ពិពាហ៍របស់ពួកគេបានលើកព្រះនាមទ្រង់អោយខ្ពស់ឡើង។ (២កូរិនថូស ៦:១៤)

8. ព្រះវរបិតាអើយ សូមរំដោះយុវជននៅនីហ្សេរីយ៉ាពីការដែលពួកគេចង់ក្លាយជាអ្នកមានតែបានដើរចូលទៅក្នុងអំពើរបាប។ ជួយពួកគេឱ្យប្រាថ្នាចង់បានតែទ្រព្យសម្បត្តិដែលពិតប្រាកដ ដែលមាននៅក្នុងទ្រង់តែមួយប៉ុណ្ណោះ។ (ម៉ាថាយ ៦:១៩-២១)

9. ព្រះអង្គអើយ សូមអោយសមាជិកក្រុមជំនុំនៅប្រទេសសេណេហ្គាល់បាននៅជាប់ជាមួយស្ត្រីក្នុងក្តីសង្ឃឹម ហើយនៅតែបន្តចូលរួមជាមួយការប្រើប្រាស់ប្រតិទិនអធិស្ឋានទាំងនេះ ដើម្បីអធិស្ឋានសម្រាប់ស្ត្រីទូទាំងពិភពលោកផងដែរ។ (កូឡូស ៤:២)

10. ព្រះបិតាអើយ សូមបំបែករាល់ទាំងចង្វាក់នៃសេពគ្រឿងស្រវឹង គ្រឿងញៀន និងអំពើសហាយស្មន់ដែលចងស្ត្រីជាច្រើននៅក្នុងប្រទេសបេនីន។ សូមឱ្យពួកគេបានរកឃើញសេរីភាពខាងឯព្រលឹងវិញ្ញាណដែលមាននៅក្នុងទ្រង់។ (ទំនុកតម្កើង ៧២:១២)

11. ព្រះវរបិតាអើយ សូមអោយស្ត្រីនៅសាធារណរដ្ឋអាហ្វ្រិកភាគកណ្តាល ដែលត្រូវបានចាត់ទុកដូចជាទាសករក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ

**TWR Korea 북방선교방송**
서울특별시 관악구 양녕로 15, 월드빌딩 6층
전화 (02)886-5671 / 이메일 hskim@twrk.or.kr

បានស្វែងរកសេរីភាព និងកម្លាំងនៅក្នុងព្រះវត្តមានរបស់ទ្រង់ នៅពេលដែលពួកគេទុកចិត្តលើទ្រង់ សូមស្តារព្រលឹងរបស់ពួកគេឡើងវិញ ព្រះអង្គអើយ។ (ទំនុកតម្កើង២៣)

12. ព្រះអម្ចាស់អើយ
សូមប្រទានប្រាជ្ញាដល់ស្ត្រីនៅប្រទេសកូតឌីវ័រក្នុងការធ្វើការងាររបស់ពួកគេ និងការមើលថែក្រុមគ្រួសាររបស់ពួកគេ។ (សុភាសិត ៣:៥)

13. ព្រះវរបិតា សូមឲ្យប្រជាពលរដ្ឋនៃប្រទេសហ្គាបុងមានការរួបរួម និងចុះសម្រុងគ្នា
ដើម្បីឱ្យពួកគេអាចដោះស្រាយការខ្វែងគំនិតគ្នាដោយសន្តិវិធី។ (១ពេត្រុស ៣:៨)

14. ព្រះអម្ចាស់អើយ
យើងអធិស្ឋានសម្រាប់ស្ថិរភាពសេដ្ឋកិច្ចនៅក្នុងប្រទេសលីបេរីយ៉ា។ សូមឲ្យប្រជាជននៅទីនោះបានសម្លឹងទៅរកទ្រង់ដើម្បីអោយបានប្រាជ្ញា សន្តិភាព និងការផ្គត់ផ្គង់តម្រូវការរបស់ពួកគេ។ (ភីលីព៤:៦-៧)

15. ព្រះជាអម្ចាស់
ទូលបង្គំអធិស្ឋានសូមអោយទ្រង់ប្រទានដល់ប្រជាជននៃប្រទេសម៉ាលី នូវការបញ្ចប់សង្គ្រាម គ្រោះធម្មជាតិ និងកត្តាផ្សេងៗទៀត ដែលនាំឱ្យមានការខ្វះខាតស្បៀងអាហារទីនោះ។ (ភីលីព ៤:១៩)

16. ឱ ព្រះវរបិតាអើយ សូមរំដោះក្រុមជំនុំនៅប្រទេសនីហ្សេរីយ៉ា ពីហោរាក្លែងក្លាយ និងគ្រូដែលបោកបញ្ឆោតមនុស្សល្ងីល្ងើ ដើម្បីផលប្រយោជន៍ និងភាពអាត្មានិយមរបស់ពួកគេ។ (ម៉ាថាយ ៧:១៥-២០)

17. ព្រះអម្ចាស់អើយ
សូមក្រាលរំលឹកគ្រីស្ទបរិស័ទនៅបេនីនដើម្បីអោយពួកគេបានជួយស្ត្រីដែលគ្មានផ្ទះសម្បែងនៅទីនោះ។
សូមនាំមកនូវដំណោះស្រាយពិតប្រាកដដល់ស្ត្រីដែលខ្វះខាតទាំងនេះ។

(ម៉ាថាយ ២៥:៣៥)

18. ឱ ព្រះវរបិតាអើយ ទូលបង្គំសូមអធិស្ឋានសុំសេចក្តីសុខសាន្ត និងការប្រោសឲ្យជានៅក្នុងផ្ទះរបស់ស្ត្រីដែលរងទុក្ខដោយអំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសកូតឌីវ័រ។ (យ៉ូហាន ១៤:២៧)

19. ព្រះដ៏ជាអម្ចាស់ សូមអនុញ្ញាតឲ្យគ្រីស្ទបរិស័ទនៅប្រទេសកាបោន ឈរយ៉ាងរឹងមាំសម្រាប់ព្រនាមរបស់ព្រះយេស៊ូវ
ហើយប្រកាសដំណឹងល្អដោយភាពក្លាហាន
ដើម្បីឲ្យព្រះបន្ទូលរបស់ទ្រង់បានសាយភាយពេញប្រទេសពួកគេផងដែរ។ (អេភេសូរ ៦:១៩)

20. ព្រះអម្ចាស់អើយ យើងខ្ញុំសូមសរសើរព្រះនាមទ្រង់ ដែលព័ន្ធកិច្ចរបស់យើងនៅប្រទេសលីបេរីយ៉ា កំពុងមានការផ្តល់ការអប់រំ និងការបណ្តុះបណ្តាលជំនាញដល់ស្ត្រីនៅទីនោះ។
សូមព្រះអង្គបានដឹកនាំអោយព័ន្ធកិច្ចមួយនេះមានការអភិវឌ្ឍបន្ថែមទៀតផងដែរ។ (សុភាសិត ៩:៩)

21. ព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ សូមទ្រង់ផ្តល់ការផ្គត់ផ្គង់ និងជំនួយខាងឯព្រលឹងវិញ្ញាណសម្រាប់ជនរងគ្រោះដោយទឹកជំនន់នៅតាមទីប្រជុំជន និងភូមិនានានៃប្រទេសម៉ាលី។ (ទំនុកតម្កើង ៩៣:៤)

22. ព្រះវរបិតាអើយ
សូមជ្រើសរើសអ្នកដឹកនាំដែលកោតខ្លាចព្រះអង្គនៅក្នុងប្រទេសនីហ្សេរីយ៉ា ដែលនឹងមានការគ្រប់គ្រងដោយយុត្តិធម៌ ជៀសវាងអំពើពុករលួយ និងសម្រាលបន្ទុកប្រជាជន។ (និក្ខមនំ ១៨:២១)

23. ព្រះជាអម្ចាស់ យើងអធិស្ឋានសុំឱ្យគូស្វាមីភរិយា
ជាពិសេសគ្រិស្តបរិស័ទនៅកូតឌីវ័របានស្វែងរកការផ្សះផ្សាជាជាងការលែងលះគ្នា។ ( ១ថែស្សាឡូនិច ៣:១២ )

24. ព្រះវរបិតា សូមប្រទានប្រាជ្ញា និងភាពច្នៃប្រឌិតដល់អ្នកដឹកនាំ និងប្រជាពលរដ្ឋនៃប្រទេសហ្គាបុង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីប្រជាជនរបស់ខ្លួនអាចរស់នៅដោយសេចក្តីថ្លៃថ្នូរផងដែរ។ (យេរេមា ២៩:១១)

25. ព្រះអម្ចាស់អើយ
សូមព្រះវិញ្ញាណរបស់ទ្រង់បានដឹកនាំអស់អ្នកដែលចូលរួមក្នុងយុទ្ធនាការនៃការផ្សាយដំណឹងល្អនៅប្រទេសម៉ាលីក្នុងរដូវរងានេះ។
សូមឱ្យមនុស្សជាច្រើនបានលឺ
និងស្គាល់ទ្រង់តាមរយៈការខិតខំមួយនេះផងដែរ។ (កិច្ចការ 28:31)

26. ព្រះអង្គអើយ
សូមជួយស្ត្រីនៅប្រទេសនីហ្សេរីយ៉ាដែលត្រូវបានរំលោភបំពាន និងកេងប្រវ័ញ្ចដោយសារភេទរបស់ពួកគេ។ (ទំនុកតម្កើង ៨២:៤)

27. ព្រះវរបិតាអើយ សូមបង្រួបបង្រួមក្រុមជំនុំនៅប្រទេសលីបេរីយ៉ា ឲ្យមានចិត្តតែមួយ
ធ្វើការរួមគ្នាក្នុងការឈោងចាប់ប្រទេសរបស់ពួកគេដើម្បីព្រះគ្រីស្ទផងដែរ។ (១កូរិនថូស ១:១០)

28. ព្រះអម្ចាស់អើយ
ទូលបង្គំអធិស្ឋានសូមអោយប្រទេសម៉ាលីទទួលបានភាពឯករាជ្យពីកម្លាំងខាងក្រៅ ក្នុងការស្វែងរកការត្រួតត្រា។
សូមអោយប្រជាជនរបស់ពួកគេបានងាកមករកទ្រង់អោយរកឃើញសទិសដៅ សន្តិភាព និងក្តីសង្ឃឹមខណៈពេលដែលពួកគេរង់ចាំការនេះ។ (ទំនុកតម្កើង ២៧:១៤)

29. ព្រះជាម្ចាស់អើយ សូមប្រទានប្រាជ្ញា
និងការយល់ដឹងកាន់តែច្រើនឡើងដល់គ្រីស្ទបរិស័ទនៅហ្គាបុង
នៅពេលដែលពួកគេមានការបង្ខំអោយបិទព្រះវិហារ។
សូមឲ្យពួកគេបានអធិស្ឋានសម្រាប់ក្រុមអ្នកដឹកនាំ
និងសមាជិកក្រុមជំនុំរបស់ពួកគេផងដែរ។ (១កូរិនថូស ១២:២៧)

30. ព្រះអម្ចាស់អើយ
សូមផ្លាស់ប្តូរដួងចិត្តបុរសៗនៅក្នុងក្រុមជនជាតិភាគតិច Holi នៃប្រទេសបេនីន ដែលមិនចង់ឱ្យប្រពន្ធរបស់ពួកគេមានជីវភាពធូរធារ ហើយព្យាយាមធ្វើឱ្យពួកគេក្រីក្រ។ (ទំនុកតម្កើង ១០៣:៦)

**후원안내**
**국민은행 851-01-0003-724 북방선교방송**
**최초 입금 후 사무실로 연락주시기 바랍니다.**